ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខៈ ៦០១៦ មស.ត្រក

ថ្ងៃ សុក្រ ២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩

សូមគោរពជូន
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង ស្ថាប័ន**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក**
**លោកស្រីអភិបាល នៃគណៈអភិបាលក្រុង ស្រុក**

**កម្មវត្ថុ** : ស្តីពីការផ្អាកការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ ក្នុងពេលកំពុងដំណើរការរៀបចំផ្ទេររចនាសម្ព័ន្ធ និងបុគ្គលិក ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**យោង** : អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឲ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

-អនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

-អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ

-អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

-អនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល ទៅឲ្យរដ្ឋបាលរាជធានី ខេត្ត

-អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ឲ្យទៅរដ្ឋបាលក្រុង ស្រុក។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពនិងជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង-ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងលោក លោកស្រី អភិបាលនៃគណៈអភិបាលក្រុង-ស្រុក មេត្តាជ្រាបថា ចំពោះមុខ ដើម្បីឲ្យដំណើរការនៃការអនុវត្តអនុក្រឹត្យ ដូចមានយោងខាងលើ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ទៅតាមពេលវេលាកំណត់

ផ្លូវវេងអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

ក្រសួងមុខងារសាធារណៈ ស្នើសុំកិច្ចសហការជាមួយក្រសួង-ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្អាកការផ្ទេរក្របខ័ណ្ឌ ឬផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិជាបណ្តោះអាសន្ន ដោយរក្សាស្ថានភាពការងារកំពុងអនុវត្តក្នុងរចនាសម្ព័ន្ធនិងបុគ្គលិកបច្ចុប្បន្នឱ្យនៅដដែលសិន រហូតដំណើរការរៀបចំផ្ទេររចនាសម្ព័ន្ធថ្មីបានធ្វើសុពលភាពរួចរាល់ ។

ដោយឡែកដំណើរការនៃការរៀបចំរបាយការណ៍ស្តីពីការប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល ក៏ដូចជាការបើកផ្តល់ប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការ ដែលកំពុងបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈ ស្នើសុំឱ្យដំណើរការជាធម្មតាសិន រហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីកំណត់ពីរចនាសម្ព័ន្ធមុខតំណែងព្រមទាំងបុគ្គលិកមកជំនួស។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួង-ស្ថាប័ន ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងលោកលោកស្រីអភិបាល នៃគណៈអភិបាលក្រុង-ស្រុក មេត្តាជ្រាប និងទទួលនូវការគោរពពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

ពេជ្រ ប៊ុនធិន

**ចម្លងជូន** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ